ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ភូមិលើ

ភូមិ : លើ
ឃុំ : ព្រះរំកិល
ស្រុក : ថាឡាបរិវ៉ាត់
ខេត្ត : ស្ទឹងត្រែង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិលើ
# រយៈពេល៣ឆ្នាំ
# (២០១១ - ២០១៣)

| | | |
|---|---|---|
| សហគមន៍នេសាទ | : | ភូមិលើ |
| ភូមិ | : | លើ |
| ឃុំ | : | ព្រះរំកិល |
| ស្រុក | : | ថាឡាបរិវ៉ាត់ |
| ខេត្ត | : | ស្ទឹងត្រែង |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**១-ស្ថានភាពទូទៅ**
**២-អំពីប្រជាសាស្ត្រ**
ក- ប្រជាពលរដ្ឋ
ខ-មុខរបរ
**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍**
ក-ទីតាំង
ខ-ដែននេសាទ
គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស
ឃ-ធនធានជលផល
**៤-ការធ្វើនេសាទ**
ក-អ្នកនេសាទ
ខ-ឧបករណ៏នេសាទ
គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ
**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**
ក-ទស្សនៈវិស័យ
ខ-គោលបំណង
គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
គ១-ផែនការប្រើប្រាស់ឧបករណ៏នេសាទ
គ២-ផែនការកែលំអរដែននេសាទ
គ៣-ផែនការរៀបចំកន្លែងអភិរក្ស
គ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក
គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ
គ៦-ផែនការអភិវឌ្ឍន៏កម្មវិធីចំរុះ
គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៏សហគមន៍
ឃ-យុទ្ធសាស្ត្រ
-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៏រយៈពេល៣ឆ្នាំ
-តារាងកម្មវិធីការងារ
-តារាងឧបសម្ពន្ធ័

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិលើ ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី ២០ ខែសភា ឆ្នាំ២០០៧ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។ សហគមន៍នេសាទភូមិលើ មានទីតាំងស្ថិតនៅក្នុងភូមិលើ ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន ២០៩នាក់ ស្រីចំនួន៩៩នាក់ និងមានគណៈកម្មការចំនួន ៧ នាក់ ស្រីចំនួន ០២នាក់។ ក្នុងនោះ ចំនួនគ្រួសារសរុបមានចំនួន ១២៧ គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

-ចុះល្បាតត្រួតពិនិត្យដែននេសាទសហគមន៍

-ប្រជុំពិភាក្សាកំណត់ព្រំប្រទល់ដែននេសាទសហគមន៍

-ចុះកំណត់ព្រំប្រទល់ដែននេសាទសហគមន៍

-ចុះកំណត់កន្លែងអភិរក្សត្រីមេពូជ

-ចូលរួមវគ្គបណ្តុះបណ្តាល

-ចូលរួមប្រជុំជាមួយភូមិ ឃុំ

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ៦១៤ នាក់ ប្រុស ២៩៤ នាក់ ស្រី៣២០ នាក់ ក្នុងនោះមាន ជនជាតិខ្មែរចំនួន ៦១៤ នាក់។

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១០នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៥ នាក់ ស្រី ៣នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣ នាក់ ស្រី ០ នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៧ នាក់ ស្រី៤នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន១ នាក់ ស្រី ១ នាក់

- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%

-ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ២៧៦នាក់ ស្រី១៤៥ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន៧២ នាក់ ស្រី៣០នាក់ មធ្យមសិក្សា ០នាក់ ស្រី ០នាក់។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៏នេះរួមមាន៖

-ធ្វើស្រែចំនួន ១០០ គ្រួសារ

-ធ្វើនេសាទ ចំនួន ១០០ គ្រួសារ

-ធ្វើចំការ(បន្លែ ឈើហូបផ្លែ ស្រូវ) ចំនួន ១០០ គ្រួសារ

-ចិញ្ចឹមសត្វ(មាន់ ទា ជ្រូក គោ ក្របី) ១០០ គ្រួសារ

-លក់ដូរចាប់ហួយចំនួន ៨ គ្រួសារ

-សេវាកម្មផ្សេងៗ ១គ្រួសារ

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក-ទីតាំង**

កន្លែងនេសាទសហគមន៏ភូមិលើមានទំហំ១១៨ហិកតានិងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។ មានព្រំប្រទល់៖

-ខាងកើតទល់និងកន្ទុយកោះលូ

-ខាងលិចទល់និងទន្លេ

-ខាងត្បូងទល់និងភូមិកណ្តាល

- ខាងជើងទល់និងភូមិអន្លង់ស្វាយ

**ខ-ដែននេសាទ**

កន្លែងនេសាទសហគមន៏ភូមិលើ

| | | | |
|---|---|---|---|
| -ទន្លេមេគង្គ | ទំហំ ១៥០០ | ហិកតា | នេសាទពេញ១ឆ្នាំ |
| -អូរថ្កៅ | ទំហំ ០,៤ | ហិកតា | នេសាទចាប់ពី៦ដល់៨ |

**គ-ធនធានជលផល**

- ប្រភេទត្រី : (ត្រីរ៉ស់ ត្រីប៉ាស៊ីអ៊ី ត្រីព្រួល ត្រីប្រា ត្រីឆ្តោ ត្រីឆ្លាំង ត្រីកេស ត្រីប៉ាវ៉ា ត្រីឆ្តោក ត្រីក្អែក ត្រីទ្រនេន ត្រីក្រសក់ ត្រីគល់រាំង ត្រីខ្វារ ត្រីរៀល ត្រីខ្លា ត្រីកញ្ចុះ ត្រីប្រមា......)។ល។

-ប្រភេទវារីសត្វ : (អណ្តើក ពស់ ខ្យង ក្តាម អន្ទង់ ខ្ចៅ កង្កែប សត្វស្លាប )។

-ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ: (រាំង ត្រស់ ត្នួរ ជ្រៃ សង្កែ ស្រឡៅ រៃ អណ្តែង ប្រជិញ ឫស្សី ចង្កែង)

## ៤-ការធ្វើនេសាទ

**ក-អ្នកនេសាទ**

-អ្នកនេសាទជាសមាជិកសហគមន៏ ចំនួន ១៤៩ នាក់ ស្រី៧៤ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៏នេសាទ នៅក្នុងសហគមន៏មានចំនួន ៤៣៥ នាក់ ស្រី ២៣៨នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ១២០នាក់ ស្រី ៦០នាក់

**ខ-ឧបករណ៍នេសាទ**

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន / គ្រួសារ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ត្រីរៀល | វង់ | ៥វង់ | ១,៥ស.ម-២,៥ស.ម/៧ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| សំណាញ់ត្រីធំ | វង់ | ៥វង់ | ៥ស.ម - ៧ស.ម/ ៨ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| មងត្រីរៀល | ហត្ថ | ៣ហត្ថ | ២ស.ម - ៣ស.ម/ ៤០ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| មងត្រីធំ | ហត្ថ | ៣ហត្ថ | ៤ស.ម - ៨ស.ម/ ៤០ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| សន្ទូច | ផ្លែ | ១០០ផ្លែ | ១០០ផ្លែ | ប្រើពេញ១ឆ្នាំ |
| លប | ចំនួន | ៣ | ១,៥ម៉ែត្រ - ២,៥ម៉ែត្រ | កក្កដា ដល់ តុលា |
| ទ្រូ | ចំនួន | ៣ | ០,៥ម៉ែត្រ- ១ម៉ែត្រ | កក្កដា ដល់ តុលា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៨០ | ១០០គីឡូក្រាម | |
| ទូកមានម៉ាស៊ិន | ៣០ | ២០០ ទៅ ៣០០គីឡូក្រាម | ៥ ទៅ ១៣ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ត្រីរៀល | វង់ | ៥វង់ | ១,៥ស.ម-២,៥ស.ម/៧ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| សំណាញ់ត្រីធំ | វង់ | ៥វង់ | ៥ស.ម - ៧ស.ម/ ៨ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| មងត្រីរៀល | ហត្ថ | ៣ហត្ថ | ២ស.ម - ៣ស.ម/ ៤០ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| មងត្រីធំ | ហត្ថ | ៣ហត្ថ | ៤ស.ម - ៨ស.ម/ ៤០ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| សន្ទូច | ផ្លែ | ១០០ផ្លែ | ១០០ផ្លែ | ប្រើពេញ១ឆ្នាំ |
| លប | ចំនួន | ៣ | ១,៥ម៉ែត្រ - ២,៥ម៉ែត្រ | កក្កដា ដល់ តុលា |
| ទ្រូ | ចំនួន | ៣ | ០,៥ម៉ែត្រ- ១ម៉ែត្រ | កក្កដា ដល់ តុលា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៩០ | ១០០គីឡូក្រាម | |
| ទូកមានម៉ាស៊ិន | ៤០ | ២០០ ទៅ ៣០០គីឡូក្រាម | ៥ ទៅ ១៣ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/គ្រួសារ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ | វង់ | ៥វង់ | ១,៥ស.ម-២,៥ស.ម/៧ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| មង | ហត្ថ | ៣ដៃ | ៥ស.ម - ៧ស.ម/ ៨ម៉ែត្រ | ប្រើពេញ១ឆ្នាំ |
| សន្ទូច | ផ្លែ | ១០០ផ្លែ | ១០០ផ្លែ | ប្រើពេញ១ឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ២០ | ១០០គីឡូក្រាម | |
| ទូកមានម៉ាស៊ីន | ៣០ | ២០០ ទៅ ៣០០គីឡូក្រាម | ៥ ទៅ ១៣ |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៥០ | ៣០ | ៨០ |
| ក្តាម ខ្យង អណ្តើក........ | | ៤០ | ៤០ |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក-ទស្សនៈវិស័យ**

សហគមន៍នេសាទភូមិកាំងក្ងោក មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ខ-គោលបំណង**

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬ កាត់បន្ថយពីឡូតិ៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក ។

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមតយៈការអភិវឌ្ឍន៏ចំរុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

**គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ទន្លេមេគង្គ | ពេញ១ឆ្នាំ | សំណាញ់<br>មង<br>លប<br>សន្ទូច | ២ស.ម-៧ស.ម<br>២ស.ម-៧ស.ម<br>១,៥ម៉ែត្រ - ២,៥ម៉ែត្រ<br>១០០ផ្លែ | ៥វង់/គ្រួសារ<br>៣ដៃ/គ្រួសារ<br>៣គ្រឿង/គ្រួសារ<br>១០០ផ្លែ | |
| អូរផ្តៅ | ខែ៦-ខែ៨ | សំណាញ់<br>មង<br>លប<br>សន្ទូច<br>ទ្រូ | ២ស.ម-៥ស.ម<br>២ស.ម-៧ស.ម<br>១,៥ម៉ែត្រ - ២,៥ម៉ែត្រ<br>១០០ផ្លែ<br>០,៥ម៉ែត្រ- ១ម៉ែត្រ | ៥វង់/គ្រួសារ<br>៣ដៃ/គ្រួសារ<br>៣គ្រឿង/គ្រួសារ<br>១០០ផ្លែ<br>៣គ្រឿង/គ្រួសារ | |

**គ២-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ**

ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម :

| សកម្មភាព | គោលបំណង | លទ្ធផលរំពឹងទុក |
|---|---|---|
| ទំនាក់ទំនងជាមួយស្ថាបន័ពាក់ព័ន្ធលើការគ្រប់គ្រងសហគមន៍នេសាទ | ដើម្បីឱ្យអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ពន្ធ័មានការចូលរួមសហការនិងជួយជំរុញការអនុវត្តឱ្យបានសមស្របតាមផែនការគ្រោងទុករបស់សហគមន៍នេសាទ | អាជ្ញាធរមូលដ្ឋាននិងស្ថាប័នពាក់ពន្ធ័មានការគាំទ្រនិងចូលរួមរាល់សកម្មភាពដែលបានអនុវត្តរបស់សហគមន៍នេសាទមានភាពទទួលខុសត្រូវស្របទៅតាមគោលការណ៍ណែនាំច្បាប់ |
| ផ្សព្វផ្សាយពីច្បាប់ជលផលថ្មីច្បាប់បទដ្ឋាននានាដែលពាក់ព័ន្ធនិងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋ | សមាជិកសហគមន៍និងប្រជាពលរដ្ឋយល់ដឹងអំពីវិស័យជលផលនិងបរិស្ថានហើយចូលរួមទប់ស្កាត់បទល្មើសនេសាទដើម្បីថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព | សមាជិកសហគមន៍និងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួមការពារ ថែរក្សា និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយ សមធម៌និងការបំផ្លាញធនធានធម្មជាតិត្រូវបានថយចុះ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែនិងត្រីមាស | ដើម្បីឆ្លុះបញ្ចាំងនិងកំណត់ផែនការដែនបានអនុវត្តពង្រឹងសម្ថភាពលើការអនុវត្តនិងរៀបចំផែនការបន្តសំដៅការអនុវត្តទទួលបានជោគជ័យ | គណៈកម្មការទទួលបាននូវបទពិសោធន៍និងចំណេះដឹងថ្មីៗលើការដោះស្រាយបញ្ហានិងមានការកែលំអរកាន់តែប្រសើរឡើង |

| | | |
|---|---|---|
| សហការជាមួយស្ថាប័នជំនាញ សម្ថកិច្ចនិងសហគមន៍ជិតខាងក្នុងការចុះបង្ក្រាបបទល្មើស០៣ដងក្នុង១ខែ | ដើម្បីបង្កើនកិច្ចសហការរវាងសហគមន៍និងអាជ្ញាធរនិងសម្ថកិច្ចពាក់ព័ន្ធក្នុងការបង្ក្រាបបទល្មើសនេសាទ | ការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយនិងត្រូវបានលុបបំបាត់នៅក្នុងសហគមន៍ភូមិ |

**គ៣-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាស់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូល សរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មី<br>-ដើរប្រមូលភាគទានតាមផ្ទះសមាជិក | ខែ០៨ឆ្នាំ២០១១<br>ខែ០៨ឆ្នាំ២០១១ | ខែ០៨ឆ្នាំ២០១៣<br>ខែ០៨ឆ្នាំ២០១៣ | | ៥០០រៀល/នាក់ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងមុនរយៈពេល១៥ថ្ងៃ<br>-ដើរប្រមូលភាគទានតាមផ្ទះសមាជិក | ពាក់កណ្ដាល ខែ១១ឆ្នាំ២០១១<br>ខែ១២ឆ្នាំ២០១១ | ពាក់កណ្ដាល ខែ១១ឆ្នាំ២០១៣<br>ខែ១២ឆ្នាំ២០១៣ | | រៀងរាល់ឆ្នាំ រយៈពេល៣ឆ្នាំ ២០០០រៀល/គ្រួសារ |

**ឃ-យុទ្ធសាស្ត្រ**

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម :

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមាន: សមាជិក គណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ

-ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ

-រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់

-ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់

ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ

-រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍

-ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ

-បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្នូមិលើ
## រយៈពេល៣ឆ្នាំ (២០១១ ដល់ ២០១៣)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក្ខ | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួញ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១-ការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍ | -សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានពេញមួយឆ្នាំ | ៧៥$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍ | | ៣០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | ចែកចាយឯកសារផែនការតាមផ្ទះ | | ៤៥$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍ | | ៩០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| ២-ការរៀបចំកន្លែងអភិរក្ស | ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | សមាជិកនិងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួមការពារថែរក្សា | ៦០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | ចុះកំណត់ព្រំប្រទល់កន្លែងអភិរក្ស | តំបន់អភិរក្សមានព្រំប្រទល់ច្បាស់លាស់ | ១៥០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | ធ្វើស្លាកសញ្ញាហាមឃាត់ចំនួន ២ផ្ទាំង | សមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួមការពារ ថែរក្សា | ៣០០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | ល្បាតជាប្រចាំកន្លែងអភិរក្ស | សមាជិកក្រុមល្បាតចូលរួមល្បាតតាមផែនការ ៣ដង/ខែ | ១០០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | ទំនាក់ទំនងជាមួយស្ថាបន័ពាក់ព័ន្ធលើការគ្រប់គ្រងសហគមន៍នេសាទ | អាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធមានការគាំទ្រនិងចូលរួមរាល់សកម្មភាពអនុវត្តនិងការអនុវត្តមានភាពទទួលខុសត្រូវស្របទៅតាម | ៣០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | គោលការណ៍ណែនាំនៃច្បាប់ | | | | | |
| ៣-ការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ផ្សព្វផ្សាយពីច្បាប់ផលផលថ្មីច្បាប់បទដ្ឋាននានាដែលពាក់ព័ន្ធនិងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋ | សមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួមការពារ ថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសមធម៌និងការបំផ្លិចបំផ្លាញធនធានត្រូវបានថយចុះ | ៩០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែនិងត្រីមាស | គណៈកម្មការទទួលបាននូវបទពិសោធន៍និងចំណេះដឹងថ្មីៗលើការដោះស្រាយបញ្ហានិងមានការកែលំអរកាន់តែប្រសើរឡើង | ៦០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| | សហការជាមួយស្ថាប័នជំនាញ សមត្ថកិច្ចនិងសហគមន៍ជិតខាងក្នុងការចុះបង្ក្រាបបទល្មើស០៣ដងក្នុង១ខែ | ការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយ និងត្រូវបានលុបបំបាត់នៅក្នុងសហគមន៍ | ៥០$ | អង្គការដៃគូ | ២០១១ | ២០១៣ | |
| ៤-ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហកមន៍ | ភាគទានពីសមាជិកសហគមន៍ | -ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មី៣០នាក់/ឆ្នាំ<br>-ដើរប្រមូលភាគទានតាមផ្ទះសមាជិក | | សហគមន៍នេសាទ | ២០១១ | ២០១៣ | |
| | ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍និងចូលរួមបង់ភាគទានប្រចាំឆ្នាំរៀងរាល់ឆ្នាំ | | សហគមន៍នេសាទ | ២០១១ | ២០១៣ | |

# តារាងកម្មវិធីការងារសកម្មភាព

| សកម្មភាព | ពេលវេលា |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
|  | ២០១១ |  |  |  |  |  |  |  |  |  |  |  | ២០១២ |  |  |  |  |  |  |  |  |  |  |  | ២០១៣ |  |  |  |  |  |  |  |  |  |  |  |
|  | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១- ការប្រើប្រាស់ឧបករណ៍នេសាទ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ១-១ ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍ |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |
| ១-២ បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |
| ១-៣ ចែកចាយឯកសារផែនការតាមផ្ទះ |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |
| ១-៤ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទ |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |
| ២-ការរៀបចំកន្លែងអភិរក្ស |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ២-១ ផ្សព្វផ្សាយពីកន្លែងអភិរក្ស |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |
| ២-២ ធ្វើស្លាកសញ្ញាហាមឃាត់ |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |
| ២-៣ ល្បាតជាប្រចាំកន្លែងអភិរក្ស | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២-៤ បោះបង្គោលព្រំប្រទល់ |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |
| ៣-ការចុះល្បាតទប់ស្កាត់បទល្មើស |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ៣-១ ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធលើការគ្រប់គ្រងសហគមន៍ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |
| ៣-២ផ្សព្វផ្សាយពីច្បាប់ជលផលថ្មីនិងច្បាប់បទដ្ឋាននានា |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |  |  |  | ■ |  |  |  |  |  |  |  |  |
| ៣-៣ ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |  |  |  |  |  | ■ |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣-៤ សហការជាមួយស្ថាប័នជំនាញសម្ព័ន្ធកិច្ចនិងសហគមន៍ជិតខាងក្នុងការចុះបង្ក្រាបបទល្មើស | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| **៤-ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤-១ ភាគទានពីសមាជិកសហគមន៍នេសាទ | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | |
| ៤-២ ភាគទានប្រចាំឆ្នាំ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ |

<u>បានឃើញនិងបញ្ជូនមក</u>
លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង
ថាឡាបរិវ៉ាត់ .ថ្ងៃទី 15 ខែ 9 ឆ្នាំ២០១០
**នាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់**
គឹម_សុខា

<u>បានឃើញ</u>
ព្រះរំកិល .ថ្ងៃទី 14 ខែ 09 ឆ្នាំ២០១០
**មេឃុំព្រះរំកិល**

លើ.ថ្ងៃទី 14 ខែ 09 ឆ្នាំ២០១០
ប្រធានគណៈកម្មការសហគមន៍នេសាទភូមិលើ
យិនខុំ

លេខ : ១៣៤៥

<u>បានឃើញ និងឯកភាព</u>
រាជធានីភ្នំពេញ .ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១០
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល** ស.ជ. ២០១
ណៅ_ធូក

លេខ : ៧៧៣ រដជ

<u>បានឃើញនិងបញ្ជូនមក</u>
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល
" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ"
ក្រចេះ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១០
**នាយអធិការដ្ឋានរដ្ឋបាលជលផលមេគង្គ**
ឡុង_គន

លេខ : ០៤១

<u>បានឃើញនិងបញ្ជូនមក</u>
លោកនាយអធិការដ្ឋានខណ្ឌរដ្ឋបាលជលផលមេគង្គ
ស្ទឹងត្រែង .ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១០
**នាយខណ្ឌ រដ្ឋបាលជលផលស្ទឹងត្រែង**
ប៉ែន ឈុនធី

# តារាងឧបសម្ព័ន្ធទី១ ធនធានធម្មជាតិក្នុងសហគមន៍នេសាទភូមិលើ

## ភូមិលើ  ឃុំព្រះរំកិល  ស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង

| ល.រ | ត្រី | | | វារីសត្វនិងសត្វស្លាប | | | វារីរុក្ខជាតិ | | |
|---|---|---|---|---|---|---|---|---|---|
| | ឈ្មោះ | កើន | ថយ | ឈ្មោះ | កើន | ថយ | ឈ្មោះ | កើន | ថយ |
| ១ | ត្រីរ៉ស់ | | √ | អណ្តើក | | √ | រាំង | √ | |
| ២ | ត្រីប៉ាសុីអុី | | √ | ពស់ | | √ | ត្រស់ | √ | |
| ៣ | ត្រីព្រួល | | | ខ្យង | | √ | ផ្ការ | √ | |
| ៤ | ត្រីប្រា | | √ | ក្តាម | | √ | ជ្រៃ | √ | |
| ៥ | ត្រីឆ្តោ | | √ | អន្ទង់ | | √ | ទន្លា | √ | |
| ៦ | ត្រីឆ្លាំង | | | ខ្ចៅ | | √ | រំដេង | √ | |
| ៧ | ត្រីកេស | | √ | កង្កែប | | √ | រ៉ៃ | √ | |
| ៨ | ត្រីប៉ាវ៉ា | | √ | កង្កែប | | √ | អណ្តែង | √ | |
| ៩ | ត្រីឆ្កោក | | √ | កុក | | √ | ប្រជិញ | √ | |
| ១០ | ត្រីក្អែក | | √ | ក្អែកគោក | √ | | ឫស្សី | √ | |
| ១១ | ត្រីទ្រនេន | | √ | ក្រៀល | √ | | ស្រូល | √ | |
| ១២ | ត្រី ត្រសក់ | | √ | សេក | √ | | ត្រែង | √ | |
| ១៣ | ត្រីគល់រាំង | | √ | លលក | √ | | អញ្ចែង . | √ | |
| ១៤ | ត្រីខ្វារ | | √ | មាន់ទឹក | √ | | សណ្តាន់ | √ | |
| ១៥ | ត្រីរៀល | | √ | ទាព្រៃ | | √ | | | |
| ១៦ | ត្រីខ្លា | | √ | ក្អែកទឹក | | √ | | | |
| ១៧ | ត្រីកញ្ចុះ | | | រំពេរ | √ | | | | |
| ១៨ | ត្រីប្រមា | | √ | ចាប | √ | | | | |
| ២០ | ត្រីអណ្តែង | | √ | សារិកាកែវ | √ | | | | |
| ២១ | ត្រីក្រហែ | | √ | ក្រសារ | | √ | | | |
| ២១ | ត្រីថ្ម | √ | | ទទា | | √ | | | |
| ២៣ | ត្រីខ្មាន់ | √ | | | | | | | |
| ២៤ | ត្រីពោ | √ | | | | | | | |
| ២៥ | ត្រីប្រាកណ្តុរ | √ | | | | | | | |
| ២៦ | ត្រីកែ | √ | | | | | | | |
| ២៧ | ត្រីខ្លាំងហាយ | | √ | | | | | | |
| ២៨ | ត្រីក្រម៉ម | √ | | | | | | | |